NOM :　　　　　　　　　　Évaluation en langue d'origine (CYCLE III) : KHMER

**DOCUMENT 1**




## *ភាសាបារាំង នៅលើពិភពលោក*

ពិភពលោកយើងសព្វថ្ងៃនេះ មានប្រជាជនចំនួន ជិត ៦ ពាន់ លាននាក់ ដែលរស់នៅក្នុងប្រទេស រឺក៏រដ្ឋ ចំនួនប្រមាណ ២០០ ។ ពួកគេទាំងនោះ និយាយ ភាសាខុសៗគ្នា ។ ភាសាមួយចំនួន ត្រូវមនុស្សចំនួនតែប៉ុន្មានពាន់នាក់ប៉ុណ្ណោះ ប្រើប្រាស់ ។ ភាសាអង់គ្លេស មានគេប្រើច្រើនជាងគេបង្អស់ សំរាប់ពាណិជ្ជកម្មអន្តរជាតិ ប៉ុន្តែភាសាចិន មានគេនិយាយច្រើនជាងគេបំផុត ។ នៅក្នុងពិភពលោក មនុស្សចំនួនជាង ២០០ លាននាក់ ប្រើភាសាបារាំង ជារៀងរាល់ថ្ងៃ : ៦០ លាននាក់ នៅប្រទេសបារាំង ហើយនៅសល់ប៉ុន្មាន នៅប្រទេសផ្សេងទៀត ដូចជាប្រទេសបែលស៊ិក ស្វីស កាណាដា និងប្រទេសមួយចំនួន នៅទ្វីបអាព្រិក ។

## *សាលាបារាំង*

នៅប្រទេសបារាំង កុមារមានករណីកិច្ចត្រូវទៅសាលារៀនរហូតដល់អាយុ១៦ឆ្នាំ ។ ជាដំបូង ពួកគេ ត្រូវរៀននៅសាលាបឋមសិក្សាសិន បន្ទាប់មកទៀត នៅអនុវិទ្យាល័យ និងចុងបញ្ចប់នៅវិទ្យាល័យ ។ កុមារមិនចាំបាច់ត្រូវតែទៅសាលាមតេយ្យ ដែលទទួលក្មេងតូចៗ អាយុក្រោម ៦ ឆ្នាំ នោះទេ ប៉ុន្តែ សាលានេះ បង្ហាត់កុមារ ឱ្យត្រៀមខ្លួន សំរាប់សាលាបឋមសិក្សា ។ មាតាបិតាសិស្ស គួរនាំកូនចុះឈ្មោះ ចូលរៀនសាលាមតេយ្យ ។ នៅសាលាបឋមសិក្សា គេទទួលបានចំណេះដឹងជាមូលដ្ឋាន មានការអាន ការសរសេរ និងការរាប់លេខ  ប៉ុន្តែ គេក៏ត្រូវរៀនភាសាបរទេសមួយ រៀនយល់ពីព័ត៌មានវិទ្យា និងអ្វីៗផ្សេងទៀត ជាច្រើន ។ ហេតុដូច្នេះហើយ បានជាគេតំរូវអោយកុមារ មករៀនទៀងទាត់ និងទាន់ពេលវេលា ។ ពេលដែលសិស្សម្នាក់ខកមិនបានមករៀន សិស្សនោះត្រូវនាំពាក្យពន្យល់របស់ឪពុកម្តាយ មកឱ្យសាលា ។ នៅសាលាបឋមសិក្សានីមួយៗ មានប្រាំថ្នាក់សិក្សា ដែលតគ្នាជាបន្តបន្ទាប់ និងដែលត្រូវទៅនឹងការសិក្សាប្រាំកំរិត ។ នេះ ជាឧទាហរណ៍ ស្តីពីកាលវិភាគ របស់ថ្នាក់រៀនមួយ ដែលមានកុមារអាយុ ៨ ឆ្នាំ :

<table>
<tr><td>០៨-៣០</td><th>ច័ន្ទ</th><th>អង្គារ</th><th>ព្រហស្បតិ៍</th><th>សុក្រ</th></tr>
<tr><td></td><td>ភាសាបារាំង</td><td>ភាសាបារាំង</td><td>ភាសាបារាំង</td><td>ភាសាបារាំង</td></tr>
<tr><td>១០-០០</td><td>គណិតវិទ្យា</td><td>គណិតវិទ្យា</td><td>គណិតវិទ្យា</td><td>គណិតវិទ្យា</td></tr>
<tr><td>១០-២០</td><td colspan="4">ចេញលេង</td></tr>
<tr><td></td><td>គណិតវិទ្យា</td><td>គណិតវិទ្យា</td><td rowspan="2">គណិតវិទ្យា</td><td rowspan="2">គណិតវិទ្យា</td></tr>
<tr><td></td><td>រៀនអាន</td><td>រៀនអាន</td></tr>
<tr><td>១១-១០<br>០១-៣០</td><td colspan="4">សំរាកញុំាអាហារថ្ងៃត្រង់</td></tr>
<tr><td></td><td>រៀនអាន</td><td>វិទ្យាសាស្ត្រ</td><td>វិទ្យាសាស្ត្រ</td><td>ប្រវត្តិសាស្ត្រ</td></tr>
<tr><td></td><td>ភូមិវិទ្យា</td><td>ព័ត៌មានវិទ្យា</td><td rowspan="3">ហែលទឹក</td><td>រៀនអាន</td></tr>
<tr><td>០៣-០០<br>០៣-២០</td><td colspan="2">ចេញលេង</td><td>ចេញលេង</td></tr>
<tr><td></td><td rowspan="2">តន្ត្រី</td><td rowspan="2">សូនរូប</td><td rowspan="2">កាយសិក្សា</td></tr>
<tr><td>០៤-៣០</td><td>កំណាព្យ</td></tr>
</table>

**សម្ភារ រឺសំលៀកបំពាក់ ដែលត្រូវយកមកជាមួយ :**

- *ហែលទឹក :* ម៉ៃយ៉ូហែលទឹក មួកពាក់សំរាប់ហែលទឹក កន្សែងពោះគោ ។
- *អប់រំកាយ :* ខោខ្លី ស្បែកជើងសំរាប់លេងតេនីស រឺលេងបាល់បោះ អាវយឺត ។
- *អាហារថ្ងៃត្រង់ នៅអាហារដ្ឋាន :* កន្សែង និងច្រាសដុសធ្មេញ ។

## សូមប្អូនឆ្លើយសំណួរខាងក្រោម ហើយគូសរង្វង់ជុំវិញចំលើយត្រឹមត្រូវ

១ **តើភាសាណាមួយ ដែលមានគេនិយាយច្រើនជាងគេ នៅលើពិភពលោក ?**

*ភាសាបារាំង ។*

*ភាសាអង់គ្លេស ។*

*ភាសាចិន ។*

២ **តើគេនិយាយភាសាបារាំង តែនៅក្នុងប្រទេសបារាំងទេ រឺ ?**

*បាទ រឺចាស ។*

*ទេ ។*

៣ **តើនៅប្រទេសបារាំង កុមារត្រូវតែទៅសាលា នៅអាយុបួនឆ្នាំ រឺ ?**

*បាទ រឺចាស ។*

*ទេ ។*

…/ 2 + …/ 2 + …/ 2 = …/6

៤ **ចូរពិនិត្យកាលវិភាគ : តើពេលចេញលេងនីមួយៗ មានរយៈពេលប៉ុន្មាន ?**

*៤០ នាទី ។*

*៣០ នាទី ។*

*៤០ នាទី ។*

៥ **តើថ្ងៃណា នៅក្នុងសប្តាហ៍ ដែលមិនមាន "រៀនអាន" ?**

*ថ្ងៃច័ន្ទ ។*

*ថ្ងៃអង្គារ ។*

*ថ្ងៃព្រហស្បតិ៍ ។*

*ថ្ងៃសុក្រ ។*

៦ **តើថ្ងៃណា ដែលកូនសិស្ស ត្រូវយកម៉ៃយ៉ូហែលទឹក និងកន្សែងពោះគោ ទៅសាលា ?**

*ថ្ងៃច័ន្ទ ។*

*ថ្ងៃអង្គារ ។*

*ថ្ងៃព្រហស្បតិ៍ ។*

*ថ្ងៃសុក្រ ។*

…../ 2 + ….. /2 + …../ 2 = …../ 6